# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# ប្រសិទ្ធិពរលើជួងនៅរោងចក្រ
# ថ្ងៃទី១១ វិច្ឆិកា ២០១៧

អត្ថបទទី១៖រម ១៦,៣-៩.១៦.២២-២៧
ដំណឹងល្អ៖លក ១៦,៩-១៥

បងប្អូនជាទីស្រឡាញ់!

ក្នុងអត្ថបទទីមួយ សន្តប៉ូលមានប្រសាសន៍ថា **សូមបងប្អូនជម្រាបសួរគ្នាទៅវិញទៅមកដោយស្និតស្នាលផង** ថ្ងៃនេះដែលយើងសូមព្រះជាម្ចាស់ប្រទានពរលើជួង ជាឱកាសមួយដើម្បីនឹកឃើញអំពីរបៀបដែលយើងជាគ្រីស្តបរិស័ទ ត្រូវតែរស់នៅក្នុងរបៀបព្រះយេស៊ូតែម្តង។ ជួងជាសញ្ញាមួយ ដើម្បីប្រមូលគ្រីស្តបរិស័ទឲ្យចូលនៅក្នុងព្រះវិហារ នៅព្រះសហាគមន៍ណាដែលមានជួង ពេលលឺគេវាយជួយយើងដឹងថាដល់ម៉ោងអធិដ្ឋានឬថ្វាយអភិបូជា។ ជាសញ្ញាមួយ ឲ្យយើងនឹកឃើញព្រះជាម្ចាស់កំពុងត្រាស់ហៅយើងឲ្យមកជួបជុំគ្នា។ ដូចយើងស្តាប់អត្ថបទថ្ងៃនេះ សូមបងប្អូនជម្រាបសួរគ្នាទៅវិញទៅមកដោយស្និតស្នាលផង ជួងណែនាំឲ្យយើងនឹកឃើញដល់ព្រះជាម្ចាស់ដែលប្រមូលយើងដើម្បីរួមគ្នាកសាងព្រះសហាគមន៍។ ជួងណែនាំឲ្យយើងជួបគ្នា ដើម្បីកសាងព្រះសហាគមន៍ដោយស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយអធិដ្ឋានយ៉ាងជិតស្និតជាមួយព្រះយេស៊ូ។ នៅពេលយើងចូលក្នុងព្រះវិហារ យើងដឹងថាព្រះយេស៊ូលើកលែងទោសឲ្យយើង ព្រះយេស៊ូបង្ហាញចិត្តមេត្តាករុណាដល់យើង ព្រះយេស៊ូត្រាស់ហៅយើងដើម្បីឲ្យយើងទៅជាព្រះសហាគមន៍គ្រួសាររបស់ព្រះយេស៊ូ ដើម្បីឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក។

ប៉ុន្មានឆ្នាំមុន ខ្ញុំបានមកសម្ពោធស្ពាននៅរោងចក្រនេះ ដែលស្ពាននេះជាសញ្ញាសម្គាល់នៃទំនាក់ទំនងរវាងគ្នានឹងគ្នា។ **ជួងជាសញ្ញាមួយទៀត ដើម្បីនឹកឃើញវត្តមានរបស់ព្រះជាម្ចាស់** ដូច្នេះយើងវាយមួយថ្ងៃបីដងគឺព្រឹក ថ្ងៃត្រង់ និងល្ងាច។ ពេលយើងលឺសម្លេងជួង យើងសូត្រធម៌ ឬអធិដ្ឋាន ដើម្បីឲ្យព្រះសហាគមន៍របស់យើងមានជីវិត។ ដើម្បីឲ្យព្រះសហាគមន៍របស់យើងទៅជាធ្លុងតែមួយ ដូចព្រះយេស៊ូថា **ខ្ញុំយាងមកដើម្បីប្រណីសន្តោសដល់បងប្អូន** ឲ្យបងប្អូនសេចក្តីស្រឡាញ់ ឲ្យបងប្អូនមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីបន្តបម្រើគ្នាទៅវិញទៅមក ដើម្បីបន្តកសាងព្រះសហាគមន៍របស់យើង។ ឲ្យព្រះសហាគមន៍

របស់យើងទៅជាគ្រួសារតែមួយ ឲ្យយើងចេះទទួលគ្នាទៅវិញទៅមក ស្រឡាញ់គ្នាទៅវិញទៅមកដោយទទួលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ។

យើងកសាងព្រះសហគមន៍រួមជាមួយគ្នា គឺព្រះសហគមន៍ដែលជាគ្រួសារតែមួយ ដែលមានចិត្តអាណិតមេត្តាដល់បងប្អូនឯទៀតៗ។ យើងធ្វើដូចម្ដេចដើម្បីជួយដល់បងប្អូនក្រីក្រ បងប្អូនដែលគ្មានទីពឹងនៅតាមភូមិជុំវិញយើង។ យើងអរព្រះគុណព្រះជាម្ចាស់ ដោយនឹកឃើញព្រះបន្ទូលម្ដងទៀត សូមបងប្អូនជម្រាបសួរគ្នាទៅវិញទៅមក ដោយស្និតស្នាលផង ដោយបងបង្ហាញថាយើងជាគ្រីស្តបរិស័ទចេះស្រឡាញ់គ្នា ចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក និងយើងជាគ្រីស្តបរិស័ទដែលអធិដ្ឋានជានិច្ច។ មួយខែទៀតយើងចូលនៅក្នុងរដូវរងចាំ យើងរងចាំព្រះយេស៊ូប្រសូត ដូច្នេះដើម្បីឲ្យយើងត្រៀមខ្លួនទទួលស្វាគមន៍ព្រះយេស៊ូ យើងត្រូវការអធិដ្ឋានជានិច្ច។ ជួងជាសញ្ញាមួយ ដើម្បីឲ្យយើងនឹកឃើញព្រះយេស៊ូ ដោយសូត្រធម៌បពិត្រព្រះនាងម៉ារី ធម៌ឱព្រះបិតា ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ដ៏វិសុទ្ធរបស់ព្រះគ្រីស្ដ។

យើងអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរ ដូចយើងបានស្ដាប់ **មានតែព្រះអម្ចាស់តែមួយព្រះអង្គគត់ដែលប្រកបដោយព្រះប្រាជ្ញាញាណ** សូមលើកតម្កើងសេរីរុងរឿងរបស់ព្រះអង្គតាមរយៈព្រះយេស៊ូគ្រីស្ដអស់កល្បជាអង្វែងតរៀងទៅ។ អាម៉ែន៕